ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ

សូមគោរពជូន

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អុន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៥៩ ឆ្នាំ ១ខែ ១០ថ្ងៃ

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ជាទីគោរព!

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសព្វសាធុការពរជ័យ បវរសួស្តី លីឬទ្ធិ ប្រុលសុខ មហាប្រសើរ ជូនចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយកក្តីរីករាយជាទីបំផុត ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៥៩ ឆ្នាំ ១ខែ ១០ថ្ងៃ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ ខាងមុខនេះ សូមទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងកាយមាំមួន បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ។

នាឱកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពកោតសរសើរយ៉ាងក្រៃលង ចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ដែលបានខិតខំប្រឹងប្រែងយកអស់ទាំងកម្លាំងកាយចិត្ত ប្រាជ្ញា ស្មារតី ប្រកបដោយតតិបណ្ឌិត ឧត្តមភាព ភាពជាអ្នកដឹកនាំ ប ំពេញបេសកកម្មជាប្រវត្តិសាស្ត្រក្នុងការបម្រើជាតិមាតុភូមិ ជាពិសេស ការចូលរួមចំណែកយ៉ាងសំខាន់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ជាមួយរាជរដ្ឋាភិបាល ពោរពេញដោយភាពស្វាហាប់ ម្ចោះមុត ដើម្បីសម្រេចបាននូវឧត្តមប្រយោជន៍ជូនជាតិ និងប្រជាជន។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមលើកដៃបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងតេជៈសក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាផ្ទាំ១ ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយការពារ និងប្រោះព្រំនូវសព្វសាធុការពរជ័យ ជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវកុសលទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អុន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ទទួលនូវការគោរពដ៏ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ[illegible] ១[illegible] ១[illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ១ ខែ [illegible] ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ សីហា

វិថីហ្សាតានីម៉ាត្រូ សង្កាត់មិត្តភាព ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២១០ email: generalsec@mod.gov.kh

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អុន ព័ន្ធមុនីរ័ត្ន
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អរគុណសន្តិភាព! អរគុណនយោបាយឈ្នះឈ្នះ!